CITY OF LONG BEACH | PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១០ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចផ្តល់ជូននូវកម្មវិធីជំនួយបន្ទាន់សម្រាប់អ្នកជួលដែលមានគុណវឌ្ឍិគ្រប់គ្រាននឹងបានរងផលប៉ះពាល់ដោយ COVID-19

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - នៅថ្ងៃនេះទីក្រុងឡុងប៊ិចបានប្រកាសនូវកម្មវិធីជំនួយថ្មីដែលត្រូវបានអនុម័តជាឯកច្ឆន្ទដោយក្រុមប្រឹក្សាក្រុងដែលនឹងផ្តល់ជំនួយដល់អ្នកជួលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងបានរងផលប៉ះពាល់ដោយជំងឺរាតត្បាត COVID-19។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "គឺជាការសំខាន់ណាស់ដែលយើងបន្តគាំទ្រដល់អ្នកជួលនិងម្ចាស់ទ្រព្យតូចៗនៅក្នុងទីក្រុងរបស់យើងនៅពេលកំពុងរងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដែលមិនធ្លាប់មានពីមុនមកដោយសារតែជំងឺរាតត្បាតនេះ។ កម្មវិធីនេះនឹងផ្តល់ជំនួយដែលត្រូវការចាំបាច់សម្រាប់ប្រជាជននិងគ្រួសារនៅឡុងប៊ិច។"

ឡុងប៊ិច CARES ដែលជាកម្មវិធីជំនួយជួលគ្រាអាសន្ន (LB CARES) នឹងផ្តល់ប្រាក់រហូតដល់ $1,000 ដុល្លារក្នុងមួយខែសម្រាប់ថ្លៃជួលដល់តែ ៣ ខែដល់អ្នកដែលរស់នៅទីក្រុងឡុងប៊ិចដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយបានបាត់បង់ប្រាក់ចំណូលដោយសារ COVID-19 និងមានប្រាក់ចំណូលទាបដូចបានកំណត់ដោយតម្រូវការសហព័ន្ធ។ ការបង់ប្រាក់ជំនួយប្រចាំខែនឹងផ្តល់ជូនម្ចាស់ដីឬម្ចាស់ផ្ទះដោយផ្ទាល់ក្នុងនាមអ្នកជួលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមកម្មវិធី។ ប្រាក់

ជំនួយនេះនិងអាចប្រើដើម្បីបង់ថ្លៃជួលដែលត្រូវទូទាត់ក្នុងកំឡុងពេលមានសិទ្ធិទទួលជំនួយគឺចាប់ពីថ្ងៃទី ២៧ ខែមីនាឆ្នាំ ២០២០ រហូតដល់ចុងបញ្ចប់នៃបទបញ្ជារក្សាសុវត្ថិភាពដោយនៅផ្ទះរបស់ទីក្រុង។

អ្នកដាក់ពាក្យសុំដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបញ្ជូនឯកសារបញ្ជាក់ពីការបាត់បង់ប្រាក់ចំណូលដែលបណ្តាលមកពីការបញ្ឈប់ការងារ កាលផ្អាកការងារមួយរយៈពេល ឬការកាត់បន្ថយម៉ោងឬប្រាក់ឈ្នួលក្នុងកំឡុងពេលជំងឺរាតត្បាត COVID-19 ចាប់ផ្តើមពីថ្ងៃទី ២៧ ខែមីនា។ រាល់ឯកសារនិងកិច្ចព្រមព្រៀងជួលនឹងត្រូវឆ្លងកាត់ការផ្ទៀងផ្ទាត់។

LB CARES ត្រូវបានផ្តល់មូលនិធិដោយទឹកប្រាក់ ៣ លានដុល្លារពីសហគមន៍អភិវឌ្ឍន៍មេរោគកូរ៉ូណា (CDBG-CV និងទឹកប្រាក់ចំនួន ២ លានដុល្លារបន្ថែមពីកម្មវិធីភាពជាដៃគូវិនិយោគ HOME ដែលចំនួនមូលនិធិត្រូវបានទុកសម្រាប់កម្មវិធីនេះ។ លើសពីនេះទៀតការិយាល័យអ្នកត្រួតពិនិត្យនៃខោនធី Los Angeles លោកស្រី Janice Hahn បានបរិច្ចាគថវិកាចំនួន ៣០ ម៉ឺនដុល្លារសម្រាប់កម្មវិធីនេះ។

លោកស្រី Janice Hahn អ្នកត្រួតពិនិត្យនៃខោនធី Los Angeles បានមានប្រសាសន៍ថា "វិបត្តិនេះបានបំផ្លាញក្រុមគ្រួសារដែលកំពុងរស់នៅក្នុងភាពក្រីក្ររួចទៅហើយ។ ខ្ញុំកំពុងចាប់ដៃគូជាមួយអភិបាលក្រុង Garcia ក្នុងការផ្តល់ជំនួយជួលដល់ប្រជាជនឡុងប៊ិចដែលត្រូវការជំនួយនិងកាត់បន្ថយការខូចខាតរយៈពេលវែងផ្នែកសេដ្ឋកិច្ចដោយសាជំងឺរាតត្បាតនេះ។"

ព័ត៌មានបន្ថែមស្តីពីកម្មវិធី LB CARES នឹងត្រូវផ្តល់ជូនចាប់ពីថ្ងៃច័ន្ទទី ១៥ ខែមិថុនាឆ្នាំ ២០២០ នៅលើគេហទំព័ររបស់ទីក្រុងតាមរយៈ៖ longbeach.gov/lbcares។ ព័ត៌មានលំអិតទាំងអស់នៃកម្មវិធីដែលរួមមានតម្រូវការមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឯកសារដាក់ពាក្យ និងកាលបរិច្ឆេទកំណត់ដើម្បីដាក់ស្នើនឹងមាននៅលើគេហទំព័រចាប់ពីថ្ងៃច័ន្ទទី ២៩ ខែមិថុនាឆ្នាំ ២០២០។

ក្នុងកិច្ចខិតខំប្រឹងប្រែងដែលពាក់ព័ន្ធក្រុមប្រឹក្សាក្រុងក៏កំពុងស្វែងរកជម្រើសជំនួយផ្សេងៗសម្រាប់ម្ចាស់អចលនៈទ្រព្យដែលបានរងផលប៉ះពាល់ដោយ COVID-19 រួមមានការជំនួយលើការរឹបអូសយកទ្រព្យសម្បត្តិការសងប្រាក់ពន្ធលើទ្រព្យសម្បត្តិនិងលទ្ធភាពនៃមូលនិធិប្រាក់កម្ចីវិល។

កាលពីខែមុនទីក្រុងឡុងប៊ិចបានយល់ព្រមពន្យារពេលបទប្បញ្ញត្តិគ្រាអាសន្នដែលបន្តការបញ្ឈប់ការបណ្តេញចេញនៃអ្នកជួលផ្ទះនិងអ្នកជួលកន្លែងពាណិជ្ជកម្មមួយចំនួន។

សូមចូលទៅមើលធនធានរបស់ទីក្រុងសម្រាប់ម្ចាស់ផ្ទះ អ្នកជួល និងម្ចាស់ដី។

សម្រាប់ព័ត៌មានថ្មីៗអំពីជម្ងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #